# ព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២នៃរាជរដ្ឋាភិបាល
- បានទ្រង់យល់ ព្រះរាជក្រម លេខ០២នស ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់កិច្ចព្រមព្រៀង ខ្មែរ- បារាំង ចុះថ្ងៃទី ២៥- ០២- ១៩៩៤ ស្តីពីការរៀបចំឡើងវិញនូវសាលាភូមិន្ទរដ្ឋបាលប្រចាំនៅកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងដោយគណៈរដ្ឋមន្ត្រីបានយល់ព្រមផងតាមរយៈការប្រជុំពេញអង្គ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៥

## ត្រាស់បង្គាប់

**មាត្រា ១** : បង្កើតសាលាភូមិន្ទរដ្ឋបាល ចំណុះទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ២** : សាលាភូមិន្ទរដ្ឋបាលមានភារកិច្ចជ្រើសរើសបណ្តុះបណ្តាល និងវិក្រឹតការមន្ត្រីរាជការដែលត្រូវគ្រប់គ្រងការងារព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣** : សាលាភូមិន្ទរដ្ឋបាល ត្រូវបានដឹកនាំដោយមន្ត្រីជាន់ខ្ពស់មួយរូប អមដោយក្រុមប្រឹក្សាភិបាល ។

**មាត្រា ៤** : លក្ខន្តិកៈនៃសាលាភូមិន្ទរដ្ឋបាល ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥** : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦** : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ និងសហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ ។

**មាត្រា ៧** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានបញ្ញត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

**នរោត្តម សីហនុ**

# II-ទីស្តីការគណៈរដ្ឋមន្ត្រី

## ១ - អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៣៨ អនក្រ**

**ស្តីពីមេបន្ទ នៃឯកជនភាវូបនីយកម្ម**

**សហគ្រាសសាធារណៈ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល